ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ០៦

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០១

**សាលដីកា**

លេខ : ០៧

ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក រៀល មួន ចៅក្រម

៤- លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

៥- លោក ប៉ែន សារឿន ចៅក្រម

ក្រឡាបញ្ជី

លោក សាន សុផាត

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

**ចំបទ** : បើកបររថយន្តធ្វើអោយអ្នកដទៃមានគ្រោះថ្នាក់ដល់ស្លាប់ ប្រព្រឹត្តនៅភូមិធ្លល់ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១-០៥-១៩៩៨ វេលាម៉ោង៥.៤០ល្ងាច ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៦០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

- ជនជាប់ចោទឈ្មោះ នាង ចន្ថន ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីបើកបររថយន្ត ទីលំនៅសព្វថ្ងៃភូមិបន្ទាយ ឃុំកណ្ដៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ឪពុកឈ្មោះ ប៉ោ ឡាច "ស្លាប់" ម្តាយឈ្មោះឡុង ណេន "រស់" ប្រពន្ធឈ្មោះកែ មុត ហៅង៉ែត មានកូន ០៣នាក់ ក្រៅឃុំ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ វ៉ា ចន្ថា (ជាចុងបណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិចំបក់ ឃុំរំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ឈួន ម៉ៅ ផ្ទេរសិទ្ធិអោយឈ្មោះ កៅ វីរៈ (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិស្វាយក្រោក ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

- កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង១៧.៤០នាទីល្ងាច ឈ្មោះនាង ចន្ទន បានបើករថយន្តឈ្នួល ម៉ាកនីសាន់ផ្លាកលេខ០០៦៧ភ៣២ ពណ៌ប្រផេះ បើកចេញពីស្វាយរៀង ឆ្ពោះទៅឃុំក្រោលគោ តាមផ្លូវជាតិលេខ១ លុះដល់ត្រង់ចំណុចតារាងយន្តហោះទល់មុខការដ្ឋានសំណង់យូណាតនៅក្នុងភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រំ ស្រាប់តែរថយន្តនេះផ្ទៀងចង្កូតទៅបុកឈ្មោះសុជាតដែលកំពុងជិះម៉ូតូលើផ្លូវថ្នល់ពីលិចទៅកើតបញ្ច្រាសទិសគ្នាខាងឆ្វេងនៃរថយន្ត បណ្ដាលអោយឈ្មោះនេះស្លាប់នៅនឹងកន្លែងមួយរំពេច ។ ក្នុងពេលនោះឈ្មោះនាង ចន្ទន ក៏បានបើកបុកម៉ាស៊ីនលាយស៊ីម៉ង់ត៍ រួចក្រឡាប់នៅទីនោះទៅ ចំណែកឈ្មោះ នាង ចន្ទន ក៏រត់គេចខ្លួនបាត់ចាប់តាំងពីពេលនោះមក ចៅក្រមស៊ើបអង្កេតបានចេញដីកាចាប់ខ្លួនលេខ៤៤ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៨ រួចហើយដែរ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តស្វាយរៀង ថា :ចោទប្រកាន់លើឈ្មោះ នាង ចន្ទន អាយុ៣៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ របររកស៊ីធ្វើស្រែ និង ស៊ីឈ្នួលបើករថយន្ត ទីលំនៅភូមិបន្ទាយ ឃុំកណ្ដៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ឪពុកឈ្មោះប៉ោ ឡាច "ស្លាប់" ម្ដាយមិនស្គាល់ឈ្មោះ ប្រពន្ធឈ្មោះកែ យ៉ុត មានកូន០៣នាក់ ទោសពីមុនគ្មាន ។ ពីបទបើកបរធ្វើអោយអ្នកដទៃមានគ្រោះថ្នាក់ ប្រព្រឹត្តនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ បទល្មើសដែលមានចែងអោយផ្ដន្ទាទោស តាមមាត្រា៦០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀង ដែលបានសំរេច :

១-ផ្ដន្ទាទោសកំបាំងមុខឈ្មោះ នាង ចន្ទន ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួនពីបទ បើកបររថយន្តខុសច្បាប់ចរាចរណ៍ បណ្ដាលអោយមានគ្រោះថ្នាក់ដល់អ្នកដទៃ "ស្លាប់" ប្រព្រឹត្តនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង៥.៤០នាទីល្ងាច បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៦០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

២-អោយឈ្មោះឈួន ម៉ៅ ម្ចាស់រថយន្តសងសំណងជម្ងឺចិត្ត និងការចំណាយធ្វើបុណ្យទានសព ព្រមទាំងសងថ្លៃម៉ូតូចំនួន១គ្រឿង ទៅអោយឈ្មោះនារី វ៉ា ចន្ថា ដើមបណ្តឹងរដ្ឋប្បវេណី ជាប្រាក់សរុបទាំងអស់ចំនួន ៧.០០០.០០០រៀល "ប្រាំពីរលានរៀល" ។ សំណើលើសពីនេះត្រូវលើកចោល តាមមាត្រា១២៥ នៃក្រិត្យច្បាប់លេខ៣៨ ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ ក្នុងប្រាក់ចំនួន៧.០០០.០០០រៀលនេះ ត្រូវដកចំនួន ៨០០.០០០រៀល សំរាប់សងទៅម្ចាស់ម៉ូតូឈ្មោះ គីម សាខន ។

៣-វត្ថុតាងមានរថយន្តនីសាន់ពណ៌ប្រផេះចំនួន០១គ្រឿង ពាក់ផ្លាកលេខ ០០៦៧ ភព ២ តួលេខ០៦៧៧៣ លេខម៉ាស៊ីន ០៨២ ៥១៣ ត្រូវរឹបអូសទុកធានាសំណងខាងលើ ។

ឯចំណែកម៉ូតូធុន១២៥ ចំនួន១គ្រឿង ដែលរងគ្រោះខ្ទិចខ្ទីនោះ ត្រូវដកហូតរួចប្រគល់ទៅអោយម្ចាស់កម្មសិទ្ធិវិញ ។

៤-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខឈ្មោះនាង ចន្ទន និង ឈ្មោះឈួន ម៉ៅ ម្ចាស់រថយន្ត ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះនារី វ៉ា ចន្ថា ។

- បើកសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង

- បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃនេះតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៨ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះឈួន ម៉ៅ ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀង លើចំណុចទី២នៃសេចក្តីសំរេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះឈួន ម៉ៅ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តំកល់សាលដីកាលេខ ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះឈួន ម៉ៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលាក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទបើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះ កៅ វីរៈ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះកៅ វីរៈ ( ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាតប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះ វ៉ា ចន្ថា ( ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :ជនជាប់ចោទឈ្មោះ នាង ចន្ថន ពិតជាបើកបរបណ្តាលអោយជនរងគ្រោះស្លាប់ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ កៅ វីរៈ ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្ញុំមានតែមួយចំនុចទេ សូមក្រុមប្រឹក្សាជំនុំជំរះបន្ថយសំណងអោយខ្ញុំបាទ ដោយក្តីអនុគ្រោះ ។

- បានស្តាប់អំណានសារណាតប របស់ឈ្មោះវ៉ា ចន្ថា ( ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : សូមតម្កល់សេចក្តីសន្និដ្ឋានខាងលើទុកនៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់លោក កៅ វីរៈ និង សារណា របស់ដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០របស់ឈ្មោះកៅ វីរៈ តំណាងឱ្យអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីឈ្មោះឈួន ម៉ៅ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ នាង ចន្ទន ពិតជាបានប្រព្រឹត្តិបទល្មើសដោយបើកបររថយន្តធ្វើឱ្យអ្នកដទៃមានគ្រោះថ្នាក់ដល់ស្លាប់ ប្រព្រឹត្តិនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង៥ ២៤០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦០ នៃច្បាប់ស្តីពីចរាចរផ្លូវគោក ។

- យល់ឃើញថា រថយន្តដែលឈ្មោះនាង ចន្ទន បើកបរនេះជាកម្មសិទ្ធិរបស់លោកឈួន ម៉ៅ ដែលតាមមាត្រា១២៦ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា លោកឈួន ម៉ៅ ត្រូវទទួលខុសត្រូវលើសំណងអំពីព្យសនកម្ម ដែលបង្កឡើងដោយនិយោជិករបស់ខ្លួន ។

- យល់ឃើញថា ការដែលតំណាងឱ្យលោកឈួន ម៉ៅ លើកឡើងអំពីសំណងលើព្យសនកម្មនោះ តុលាការកំពូលពុំអាចពិចារណាបានឡើយ ។

- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួន ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកទទួលខុសត្រូវសំណង**

**រដ្ឋប្បវេណីកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះកៅ វីរៈ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ។